Theology on the Web.org.uk
Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

សំណុំនិគហ្គរុំ ៤/១ (មករា ២០០៣): ១៣៧-១៥៧



# ព្រះជាម្ចាស់ផ្លាស់ក្ដីទុក្ខសោកមកជារបាំ (សេចក្ដីអំណរឡើងវិញ)

*គីមខាន់ ណូរ៉េន*
(ដែលពីមុនគេស្គាល់ថាឈ្មោះ តែ ខុនណាង)

នៅពេលខ្ញុំក្រឡេកមើលជីវិតខ្ញុំពីមុនមក ខ្ញុំអាចឃើញព្រះជាម្ចាស់ទ្រង់ល្អក្រៃលែង ទ្រង់បានធ្វើអន្តរាគមន៍រំដោះជីវិតខ្ញុំឲ្យរួចពីការអស់សង្ឃឹម និងរួចពីគ្រោះមហន្តរាយផ្សេងៗម្ដងហើយម្ដងទៀត ។ ដោយឆ្លុះបញ្ចាំងលើពាក្យសម្ដីរបស់ស្ដេចដាវីឌ នៅក្នុងគម្ពីរទំនុកដំកើង ៣០:១១ ខ្ញុំមើលឃើញជីវិតរបស់ខ្ញុំមកដល់ក៏រឹតដូចជាស្ដេចដាវីឌ បានរៀបរាប់ពិតប្រាកដមែន គឺច្បាស់ណាស់ព្រះជាម្ចាស់បានផ្លាស់ប្ដូរទុក្ខសោករបស់ខ្ញុំទៅជារបាំ (ទៅជាអំណរឡើងវិញ) ។

កាលខ្ញុំនៅតូចមានម្ដងនោះខ្ញុំបានធ្លាក់ទៅក្នុងស្ទឹង ហើយស្ទើរតែលង់ទឹកស្លាប់ ។ ប៉ុន្តែព្រះបានផ្ដល់ប្រាជ្ញាដល់ខ្ញុំ ឲ្យខ្ញុំបានប្រើជើងខ្ញុំធាក់ដីបាតស្ទឹង ដើម្បីឲ្យខ្ញុំបានងើបផុតពីផ្ទៃទឹកសំរាប់ដកដង្ហើមពីមួយពេល ទៅមួយពេល បន្ទាប់មកព្រះជាម្ចាស់ប្រទានសត្វទាមួយហ្វូងតូចចុះមកហែលនៅពីមុខខ្ញុំបណ្ដោយទឹកហូរ ដើម្បីទាញអារម្មណ៍មនុស្សដែលនៅលើស្ពានឲ្យយល់ថាខ្ញុំហែលតាមចាប់ទា ដោយសារព្រះគុណ

ព្រះជាម្ចាស់ មានសាច់ញាតិម្នាក់បានឃើញខ្ញុំមុជងើបៗនៅក្នុងទឹក ក៏យល់ថាខ្ញុំលង់ទឹក ហើយបានប្រញាប់ប្រញាល់មកសង្គ្រោះខ្ញុំ ។

ខ្ញុំមិនដែលបានស្គាល់ឪពុកខ្ញុំសោះ ពីព្រោះគាត់បានស្លាប់នៅដែលខ្ញុំអាយុបាន៦ខែ ប៉ុន្តែខ្ញុំមានភាពស្និទ្ធស្នាលជាមួយម្ដាយខ្ញុំណាស់ បន្ទាប់មកពេលដែលខ្ញុំអាយុ បាន៨ឆ្នាំ ម្ដាយខ្ញុំក៏ស្លាប់ទៀត ។ នៅពេលដែលគាត់ត្រដររខ្យល់ដង្ហើមចុងក្រោយរបស់គាត់នៅក្នុងអង្រឹង ខ្ញុំបានគេងជិតអង្រឹងរបស់គាត់ ហើយខ្ញុំក៏និមិត្តឃើញសត្វស្វាដ៏អាក្រក់ពីរធំៗសែងអង្រឹងម្ដាយខ្ញុំចេញទៅ ។ ខ្ញុំឃើញខ្លួនខ្ញុំរត់តាមសត្វស្វាទាំងពីរនោះហើយស្រែកយំ សុំឲ្យសត្វនោះនាំយកម្ដាយខ្ញុំមកវិញ ។ ស្រាប់តែខ្ញុំឃើញអណ្ដូងជ្រៅៗជាច្រើនដូចជាអំបែងនំគ្រក់នៅឆ្វេងស្ដាំ និងនៅខាងមុខខ្ញុំ ហើយនៅក្នុងអណ្ដូងនិមួយៗមានពាសពេញទៅដោយសត្វស្វាដ៏អាក្រក់ជាច្រើនរាប់លានក្បាលគួរព្រឺក្បាលណាស់ សត្វស្វាបានសែងអង្រឹងម្ដាយខ្ញុំឆ្ងាយទៅៗចូលក្នុងភាពងងឹត ខ្ញុំស្រែកយំដង្ហើយកាន់តែខ្លាំងឡើងៗរកម្ដាយខ្ញុំឲ្យមកវិញ ស្រាប់តែរំពេចនោះខ្ញុំលឺសូរសំលេងម្ដាយខ្ញុំស្រែកហាមខ្ញុំថា "ឈប់សិន! កុំមកតាមម្ដាយអី កុំសាកល្បងតាមទៀតអី ប្រយ័ត្នធ្លាក់អណ្ដូង ចូលទៅវិញទៅ" ។ ពេលខ្ញុំភ្ញាក់ឡើង សាច់ញាតិខ្ញុំបានប្រញាប់ប្រញាល់យកម្ដាយខ្ញុំទៅមន្ទីរពេទ្យ ប៉ុន្តែហួសពេលហើយ ។ ជីដូនខ្ញុំបានប្រាប់ថា ម្ដាយខ្ញុំបានស្លាប់ហើយ ។ ហើយពួកគាត់បានកប់ម្ដាយខ្ញុំចូលក្នុងដី ។ នៅពេលនោះ ទំហំនៃទុក្ខសោករបស់ខ្ញុំវាធំហួស រហូតដល់ទៅយំក៏មិនចេញ ។

ប៉ុន្តែខ្ញុំជឿថា ព្រះជាម្ចាស់បានប្រើនិមិត្តអំពីឋាននរកនោះឲ្យខ្ញុំឃើញ ដើម្បីរៀបចំជីវិតរបស់ខ្ញុំឲ្យទទួលសេចក្ដីសង្គ្រោះនៅពេលក្រោយ ។ ពេលដែលវ័យខ្ញុំកំពុងតែចំរើនឡើង ខ្ញុំបានចាប់ចិត្តជាខ្លាំងចំពោះកំណាព្យបុរាណ និងរឿងបុរាណដែលម្ដាយ និងលោកយាយរបស់ខ្ញុំ

បានបង្រៀន ។ ជាពិសេស គឺលោកយាយរបស់ខ្ញុំចូលចិត្តទៅមើល ល្ខោនបុរាណណាស់ គាត់តែងតែនាំខ្ញុំទៅជាមួយគាត់ជានិច្ច ។ ខ្ញុំក៏ ដូច្នោះដែរ ខ្ញុំ ចូលចិត្តយ៉ាងខ្លាំងចំពោះផ្ទាំងគំនូរដ៏មានតម្លៃដែលចែងរឿង ជីវប្រវត្តិរបស់ព្រះពុទ្ធ ដែលគូរនៅលើជញ្ជាំងវិហារនៅវត្ត ។ ហើយនៅ សាលារៀន ខ្ញុំបានរៀនចេះសិល្បៈបុរាណផ្សេងៗខ្លះៗ ដូចជារបាំបុរាណ និងចម្រៀងបុរាណ ។

បន្ទាប់ពីម្តាយរបស់ខ្ញុំបានស្លាប់ទៅ លោកយាយរបស់ខ្ញុំបានថែ រក្សាខ្ញុំ ។ គាត់ជាលោកយាយដែលមានចិត្តល្អណាស់ ។ ខ្ញុំ ស្រឡាញ់គាត់ខ្លាំងណាស់ ។ ប៉ុន្តែពេលដែលខ្ញុំអាយុបាន១៣ឆ្នាំ លោក យាយរបស់ខ្ញុំក៏បានស្លាប់ទៀត ។ ម្តងហើយម្តងទៀត សេចក្តីស្លាប់បាន បំបែកខ្ញុំពីមនុស្សដែលខ្ញុំស្រឡាញ់ ។

បន្ទាប់ពីនោះមក គ្មាននរណាកំឡាទឹកចិត្តខ្ញុំឲ្យចាប់អារម្មណ៍ពី សិល្បៈទៀតឡើយ ។ ខ្ញុំបានរស់នៅក្រោមអំណាចដ៏តឹងរឹងរបស់ម្តាយ មីងបង្កើតរបស់ខ្ញុំ ។ គាត់ចិញ្ចឹមខ្ញុំហាក់ដូចជាទាសករ មិនមែនជាសាច់ ញាតិជិតដិតឡើយ ។ ខ្ញុំបានធ្វើការផ្ទះសព្វគ្រប់បែបយ៉ាង និងមូរបារីលក់ ទាំងយប់ទាំងថ្ងៃក្នុងមុខជំនួញរបស់គាត់ ដោយពុំសូវមានពេលនឹងធ្វើ មេរៀនពីសាលា ហើយក៏គេងមិនគ្រប់គ្រាន់ដែរ ។

ពេលខ្ញុំបានធំដឹងក្តីបន្តិចមក ខ្ញុំបានសំរេចចាកចេញពីម្តាយមីង ដែលនៅខេត្តសៀមរាប មករស់នៅជាមួយបងប្រុសបង្អស់របស់ខ្ញុំនៅ ភ្នំពេញ ដើម្បីនឹងប្រលងបញ្ចប់ការសិក្សា ប្រលងយកសញ្ញាប័ត្រមធ្យម សិក្សាទុតិយភូមិ ។ ប៉ុន្តែរយៈពេលនោះបងប្រុសខ្ញុំបានរៀបការប្រពន្ធ ហើយ គាត់គ្មានពេលនឹងយកចិត្តទុកដាក់ជាមួយខ្ញុំទេ ហើយប្រពន្ធ គាត់ក៏ពូកែរករឿងខ្ញុំទៀត និងរឿងរ៉ាវក្នុងគ្រួសារជាកង្វល់យ៉ាងខ្លាំង ដែលមិនអនុញ្ញាតឲ្យខ្ញុំរៀនតទៅមុខបានទៀត បន្ទាប់មកខ្ញុំបានសញ្ញាប័ត្រ

មធ្យមសិក្សាទុតិយភូមិ រួចហើយខ្ញុំបានសំរេចចិត្តថា ខ្ញុំអាចថែរក្សាខ្លួនខ្ញុំបានហើយ ខ្ញុំមិនត្រូវការអ្នកណាឲ្យចិញ្ចឹមខ្ញុំទៀតទេ ។ ខ្ញុំក៏បានស្វែងរកផ្លូវសំរាប់ជួយខ្លួនឯង ក៏បានប្រឡងជាប់ចូលមជ្ឈមណ្ឌលគរុកោសល្យកំពង់កន្ទួត ហ្វឹកហ្វឺនជាគ្រូបង្រៀននៅទីនោះពីរឆ្នាំ ។ បន្ទាប់ពីទទួលសញ្ញាប័ត្រគ្រូបង្រៀនរួចមកខ្ញុំបានជ្រើសរើសចូលទៅបង្រៀននៅខេត្តកំពតដែលនៅទីនោះខ្ញុំបានជួប ហើយរៀបការជាមួយប្តីខ្ញុំឈ្មោះ គឹម សាលីន ក្នុងឆ្នាំ ១៩៦៧ ។ ជីវិតអាពាហ៍ពិពាហ៍របស់យើងមានសុភមង្គលណាស់ពេលនោះហើយដែលយើងមានកូនល្អៗបីនាក់ កូនប្រុសបងឈ្មោះ សាលីណា កូនស្រីទីពីរ លក្សី និងកូនស្រីពៅឈ្មោះ សុវណ្ណា ។

ក្នុងឆ្នាំ ១៩៧០ សង្គ្រាមនៅអាស៊ីភាគអាគ្នេយ៍បានចាប់ផ្តើមរាលដាលមកលើប្រទេសអព្យាក្រឹត្យកម្ពុជា ដូច្នោះហើយបានជាពួកយើងផ្លាស់ទីលំនៅពីខេត្តកំពត មកនៅក្រុងភ្នំពេញ ។

នៅថ្ងៃមួយក្នុងខែធ្នូ ឆ្នាំ ១៩៧៤ មិត្តភក្តិខ្ញុំឈ្មោះ អ្នកគ្រូ វ៉ា បានអញ្ជើញខ្ញុំទៅព្រះវិហារយេស៊ូជាមួយគាត់ ។ ដំបូងខ្ញុំសួរគាត់ថា "ទៅធ្វើអី?" ។ ប៉ុន្តែគាត់បានប្រាប់ខ្ញុំអំពីច្បាប់របស់ព្រះយេស៊ូគ្រីស្ទ "កាលណាអ្នកធ្វើទាននោះកុំឲ្យដៃឆ្វេងយល់ការពីដៃស្តាំធ្វើឡើយ" ពាក្យទាំងនោះត្រូវចិត្តខ្ញុំណាស់ ព្រោះខ្ញុំមិនសូវចូលចិត្តចរិកលក្ខណៈរបស់មនុស្សខ្លះ ដែលបានដាក់លុយធ្វើបុណ្យនៅវត្តសំរាប់តែបង្ហាញអំនួតរបស់គេតែប៉ុណ្ណោះ ច្បាប់របស់ព្រះយេស៊ូហាក់ដូចជាល្អណាស់សំរាប់ខ្ញុំ ។ ហើយខ្ញុំក៏បានយល់ព្រមទៅព្រះវិហារជាមួយមិត្តភក្តិខ្ញុំនៅពេលនោះ ។

គ្មានអ្នកណាមួយឲ្យព្រះគម្ពីរមកខ្ញុំទេ ហើយដោយព្រោះខ្ញុំមិនបានទៅរៀនព្រះគម្ពីរនៅព្រះវិហារ ចំណេះចេះដឹងអំពីព្រះជាម្ចាស់របស់ខ្ញុំមានតិចតួចណាស់ ប៉ុន្តែកូនតូចៗរបស់ខ្ញុំបានរៀនចេះដឹងច្រើន ។ នៅផ្ទះគេធ្លាប់បានលេងជារឿងព្រះ ជួនកាលគេបានលេងរឿងព្រះគម្ពីរ ជួន

កាលគេបានលេងរឿងជាអ្នកផ្សាយព្រះបន្ទូល ឬជួនកាលទៀតគេបានលេងដើរតួជាព្រះតែម្តង ។ ខ្ញុំក៏បានសិក្សាអំពីរឿងព្រះពីកូនខ្ញុំបានខ្លះ ដែរ។

ក្នុងខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានលុកលុយដល់ភ្នំពេញ បានសំលាប់មនុស្សក្នុងជួររដ្ឋាភិបាល និងមនុស្សដែលមានចំណេះដឹងផ្សេងៗ អ្នកមានទ្រព្យ ឬអ្នកដែលជាប់ទាក់ទងនឹងពួកសេរី ។ បន្ទាប់មក គេបញ្ជាឲ្យប្រជាជន និងមនុស្សទាំងអស់ដែលសល់ពីស្លាប់ឲ្យចេញទៅរស់នៅជនបទតែម្តង ។ ប្តីខ្ញុំមានមុខងារជាអនុសេនីឯកក្នុងជួរកងទ័ព ។

ពេលគាត់មកដល់ផ្ទះវិញនៅថ្ងៃដែលខ្មែរក្រហមឈ្លានពាន ខោអាវឯកសណ្ឋានទាំងអស់ រូបថត ឬឯកសារផ្សេងៗដែលអាចធ្វើឲ្យគាត់ជាប់ទោសឧក្រិដ្ឋរបស់ខ្មែរក្រហម ដោះយកទៅចោលក្នុងថ្លុកជិតផ្ទះ ។ បន្ទាប់មក គាត់បានលាក់សៀវភៅរូបថតរៀបការនឹងរូបថតគ្រួសារនៅលើពិដានក្រោមដំបូលផ្ទះ រួចហើយបានរៀបចំកង់មួយដាក់ឥវ៉ាន់ យើងបានចាក់សោផ្ទះ រួចចេញពីភ្នំពេញទៅជនបទជាមួយនឹងកូនច្បងទាំងពីរ។

ឯកូនឈ្មោះ សុវណ្ណ បានទៅនៅជាមួយសាច់ញាតិខាងប្តីខ្ញុំ ។ តាំងពីនោះមកខ្ញុំមិនដែលបានឃើញស្រីពៅ និងសាច់ញាតិនោះទៀតទេ ។ នៅតាមផ្លូវក្នុងទីក្រុងភ្នំពេញ ទាហានខ្មែរក្រហមបានធ្វើបាបប្រជាជនដូចជាសត្វធាតុ ។ ត្រូវវាយក៏វាយ ត្រូវបាញ់សម្លាប់ចោលក៏សម្លាប់ភ្លាមតាមតែអំណាចរបស់ខ្លួនដែលមានកាំភ្លើង ។

តាមដងផ្លូវដែលយើងបានដើរចេញពីទីក្រុង យើងបានឃើញសាកសពមនុស្សដែលស្លាប់នៅពេញពាសកន្លែង ។ មានសពមនុស្សម្នាក់បានដេកនៅកណ្តាលផ្លូវ យើងបានដើរជៀសសពនោះយ៉ាងលឿន ហើយខំប្រឹងធ្វើដំណើរទៅមុខទៀត ប៉ុន្តែរំពេចនោះសម្លេងដែលពេញទៅដោយទឹកភ្នែករបស់ លក្ស្មី កូនស្រីរបស់យើងនៅក្រោយខ្នងយើង "ពូ

ក្រោកឡើងគេទៅចោលអស់ហើយ កុំគេងអីចឹង" ខ្ញុំស្រែកហៅកូន ស្រីខ្ញុំថា "លក្ស្មី ខ្មោច កុំហៅ គាត់ស្លាប់ហើយ" ពេលនោះ លក្ស្មីមានការភ័យខ្លាចយ៉ាងខ្លាំងបែរមករកខ្ញុំ ហើយបានស្រែកទាំងយំយ៉ាងខ្លាំងថា "ខ្ញុំមិនចង់ស្លាប់ទេ!" ប្ដីខ្ញុំបានរត់ទៅអោបលើកនាងពឡើង ផ្ដេកក្បាលនាងលើស្មា អង្អែលក្បាលនាងថ្នមៗ នាងនៅតែយំសស្រាក់នៅលើដៃគាត់ ពេលគាត់បែរមុខមករកខ្ញុំ ខ្ញុំបានឃើញទឹកភ្នែកគាត់ហូរដូចទឹកជ្រោះ នោះជាលើកទីមួយហើយដែលខ្ញុំបានឃើញប្ដីខ្ញុំស្រក់ទឹកភ្នែក ។ ពួកយើង និងប្រជាជនជាច្រើនត្រូវបានគេជម្លៀសឆ្ងាយទៅៗពីទីក្រុងរហូតទៅដល់ភូមិបាក់បែកមួយ ហើយគេដាក់ពួកយើងឲ្យធ្វើការនៅទីនោះ ។

យើងត្រូវជួសជុលសង់ខ្ទមដោយខ្លួនឯង មុននឹងចូលទៅធ្វើការនៅស្រែដែលគ្មានសម្ភារៈអ្វីនឹងធ្វើស្រែសោះ ។ ព្រោះខ្មែរក្រហមដែលនៅភូមិបាក់បែកនោះទើបតែនឹងចុះមកពីភ្នំដែរ មានតែស្រូវនិងអង្ករ គ្មានម្ហូប អំបិលប្រហុក ខោអាវមានតែមួយចង្កេះៗនោះខ្លះច្រៀកង៉ៀត ។ ពេលនោះពួកយើងបានយកសម្ភារៈខ្លះៗមកជាមួយដូចជា កាំបិត វណាផ្កាក់ ថ្នាំពេទ្យ អង្ករ ម្ហូបកំប៉ុង ម្ហូបក្រៀម និងអំបិលប្រហុកជាច្រើនទៅជាមួយញ៉ាំរាប់ខែ ប៉ុន្តែអ្នកដឹកនាំខ្មែរក្រហមបានស្នើរសុំអស់ជាច្រើនយកតាំងពីកង់ដែលជាយានជំនិះរបស់យើងផងដែរ ។

បន្ទាប់មកគេបានជម្លៀសយើងទៅមុខទៀត ទៅដាក់លើភ្នំដែលមានសុទ្ធតែដើមឫស្សី ទៅដល់ទីណាគេឲ្យពួកយើងសង់ខ្ទមនៅទីនោះ មុខងាររបស់ពួកយើងជាប្រចាំ គឺកាប់ដើមឫស្សីដុតចោល ។ គេចែកអង្ករឲ្យពួកយើងតិចតួចណាស់ ហើយម៉ោងធ្វើការក៏វែង ឯកូនក្មេងក៏ត្រូវធ្វើការដែរ ។ គឺនៅទីនោះហើយដែលយើងទាំងអស់គ្នាចាប់ផ្ដើមឈឺ ជាពិសេសគឺកូនប្រុសខ្ញុំ សាលីណា ។

ក្រោយមកទៀត គេក៏បញ្ជូនពួកយើងពីខេត្តកំពង់ស្ពឺ ទៅខេត្តពោធិសាត់ ហើយយកយើងទៅដាក់ក្នុងព្រៃជ្រៅ ។ នៅក្នុងព្រៃ នៅតាម ផ្លូវ កូនប្រុសខ្ញុំសាលីណាបានចាប់ផ្ដើមទន់ខ្សោយមែនទែន សាលីណាមិនអាចដើររួចទៀតទេ គេបានអង្គុយចុះនៅកណ្ដាលផ្លូវ ឯប្ដីខ្ញុំនិងខ្ញុំក៏ចុះខ្សោយខ្លាំងដែរ ក្នុងការរែកពុនសំភារៈប្រើប្រាស់ និងហូបចុក ហើយគាត់ពិបាកនឹងពសាលីណាបន្ថែមទៀតដែរ ។ ដើម្បីកំឡាទឹកចិត្តឲ្យសាលីណាប្រឹងក្រោកឡើងដើរដោយខ្លួនឯង ប្ដីខ្ញុំបានប្រាប់ខ្ញុំឲ្យដើរតាមផ្លូវបត់ឲ្យផុតភ្នែកសាលីណា ចាំមើលក្រែងសាលីណាអាចខំប្រឹងក្រោកដើរមកតាមពួកយើង ប៉ុន្តែសាលីណាមិនអាចក្រោករួចឡើយ ។

លក្ស្មីឈរនៅកាច់ជ្រុងផ្លូវដោយអន្ទះសា ស្រែកហៅបងប្រុសនាងថា បងទីនក្រោកឡើងម៉ែគាត់ទៅចោលហើយ នាងងាកមករកយើងទាំងពីរ ហើយស្រែកថា "ចាំបងទីនផង គាត់ក្រោកមិនរួចទេ ឈប់ដើរទៀតទៅ" ។ ពេលដែលយើងដឹងច្បាស់ថា សាលីណាមិនអាចជួយខ្លួនឯងបាន យើងបានដើរត្រឡប់ទៅយកសាលីណា ប្ដីខ្ញុំក៏លើកសាលីណាដាក់លើគាត់ ដែលគាត់មានឥវ៉ាន់ធ្ងន់ណាស់ទៅហើយនោះ ។

ពេលដែលយើងមកដល់ខេត្តពោធិសាត់ រឿងដែលកើតមានឡើង គឺត្រូវសង់ខ្ទមដោយខ្លួនឯង ត្រូវចុះឈ្មោះទៅធ្វើការនៅស្រែ យើងបានឃើញទិដ្ឋភាពរន្ធត់ជារៀងរាល់ថ្ងៃ គេសែងមនុស្សស្លាប់ចេញពីខ្ទមមួយទៅខ្ទមមួយយកទៅកប់នៅក្នុងព្រៃ ។ យើងរស់នៅទីនោះមិនបានប៉ុន្មានផង អ្នកដឹកនាំខ្មែរក្រហមនៅទីនោះ បានផ្លាស់ប្ដីរបស់ខ្ញុំឲ្យទៅធ្វើការនៅកន្លែងមួយទៀត ។ ក្នុងរយៈកាលនោះ ផ្លែញញួទុំក្នុងព្រៃជាសញ្ញានៃការស្មោះត្រង់របស់ព្រះជាម្ចាស់សំរាប់រូបខ្ញុំ ។ ពេលខ្ញុំបានធ្វើការនៅក្នុងព្រៃនៅខេត្តពោធិសាត់នោះ មានដើមញញួជាច្រើនដុះដេរដាសនៅតាមផ្លូវដែលខ្ញុំដើរទៅស្រែ ។ រាល់ព្រឹក ខ្ញុំដើរចេញ

ទៅធ្វើការដោយគ្មានអាហារពេលព្រឹកសោះ ខ្ញុំឃ្លានណាស់ក៏បានរត់ទៅបេះផ្លែញិញដែលទុំក្នុងព្រៃនោះ ខ្ញុំតែងតែរកបេះបានផ្លែទុំយ៉ាងល្អមួយរៀងរាល់ព្រឹក គឺជាវីតាមីនដែលជួយឲ្យខ្ញុំរស់បាននៅពេលនោះ ។

សូម្បីតែខ្ញុំបានឈឺរហូតដល់ទៅពីរដង ដែលត្រូវបញ្ជូនទៅមន្ទីរពេទ្យដែលអ្នកជំងឺទៅសំរាប់តែស្លាប់ប៉ុណ្ណោះ តែពេលដែលខ្ញុំនៅទីនោះ កូនខ្ញុំទាំងពីរបានអង្គុយជិតខ្ញុំ កំឡាទឹកចិត្តខ្ញុំដោយរំឭកអំពីជីវិតនៅ ភ្នំពេញដែលជាជីវិតដ៏សម្បូរអ្វីៗសំរាប់ហូប ពេលម្តងៗដែលខ្ញុំចេញពី មន្ទីរពេទ្យ គឺខ្ញុំមិនអាចដើររួចដោយខ្លួនឯង គឺដើរដោយពឹងលើឈើច្រត់ពីរសំរាប់ទប់ខ្លួន ។

លើកទីមួយ ប្តីខ្ញុំបានត្រឡប់មកលេងនឹងខ្ញុំ ព្រមទាំងកូនបន្ទាប់ពីបានឃ្លាតចេញពីពួកយើងលើកទីមួយអស់រយៈពេលប្រាំមួយខែ ។ គាត់បានកើតទុក្ខជាខ្លាំង ដោយឃើញពួកយើងស្គមស្គាំង ហើយទន់ខ្សោយ ។ ក្នុងរយៈកាលពីរអាទិត្យដែលគាត់នៅជាមួយពួកយើង គាត់បានដាំដំណាំជុំវិញផ្ទះយើង ដោយប្រើគ្រាប់ពូជដែលគាត់យកជាប់មកជាមួយ ។ គាត់បានយកគ្រឿងប្រើប្រាស់ច្រើនទៀតមកឲ្យពួកយើង ជាពិសេសសាច់ជូរដែលសំរាប់ផ្សំធ្វើថ្នាំព្យាបាលរោគបាន ។ នៅពេលនោះ គាត់បានអង្វរឲ្យរត់ទៅជាមួយគាត់ ហើយភៀសខ្លួនទៅប្រទេសថៃ ខ្ញុំប្រាប់គាត់ថាមិនអាចទៅបានទេ ព្រោះយើងទាំងបីនាក់គ្មានកម្លាំងនឹងធ្វើដំណើរឡើយ ។ បន្ទាប់មកក៏ដល់ពេលដែលគាត់ត្រូវត្រឡប់ទៅកន្លែងគាត់វិញ ហើយពួកយើងទាំងបីនាក់ក៏ត្រូវនៅជាឯកោម្តងទៀត ។

ប្រហែលជាខែមិថុនា ឆ្នាំ ១៩៧៦ ដែលកូនប្រុសច្បងរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង ដោយជំងឺរាកមួល ។ បន្ទាប់មកជំងឺកាន់តែជាបធ្ងន់ឡើងៗ កម្លាំងកាន់តែខ្សោយទៅៗ ហើយខ្ញុំបានភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលកូនខ្ញុំបាននិយាយថា "ម៉ែៗ ខ្ញុំមិនចេះរស់នៅក្នុង

សង្គមពុករលួយនេះតទៅទៀតទេ អ្នកអាក្រក់ឈ្នះអ្នកល្អ អ្នកធំជិះជាន់ អ្នកតូច ខ្ញុំបាទចង់ទៅរស់នៅជាមួយព្រះយេស៊ូនៅឋានសួគ៌ តើឲ្យខ្ញុំទៅ ឬទេ?" នៅពេលនោះខ្ញុំមិនសូវមានចំណេះអំពីបទគម្ពីរទេ ខ្ញុំក៏មិនសូវ យល់អ្វីដែលកូននិយាយផងដែរ ប៉ុន្តែខ្ញុំបានឆ្លើយតបថា មានអីបើកូន សប្បាយចិត្តនឹងទៅជាមួយព្រះយេស៊ូនោះ ឥឡូវញ៉ាំពោតនេះទៅដើម្បី ឲ្យបានឆ្ងាញ់មាត់បន្តិច ជាចុងក្រោយបង្អស់មុននឹងឯងលាចាកលោកនេះ ទៅ ។ សាលីណា មានទឹកមុខមាំមួនសម្លឹងមើលមុខខ្ញុំយ៉ាងស្កប់ចិត្ត ទទួលយកពោតពីដៃខ្ញុំ ហើយបេះញ៉ាំតែបីគ្រាប់រួចហុចពោតមកឲ្យខ្ញុំវិញ បន្ទាប់មកក៏បែរមុខទៅជញ្ជាំង ហើយសម្ងំគេងទៅ ប៉ុន្តែសាលីណាមិន ភ្ញាក់វិញទេ ។ ពេលព្រឹកឡើង រូបរាងកាយដ៏តូចមួយរបស់សាលីណា ត្រូវបានគេសែងទៅកប់ក្នុងព្រៃបាត់ទៅ ។

មួយអាទិត្យក្រោយមក លក្សិ៍មានជម្ងឺគ្រុនចាញ់កាន់តែដាបឡើង ។ ប៉ុន្តែសេចក្តីស្លាប់របស់នាងខុសពីសាលីណា ។ មុននឹងដាច់ខ្យល់ នាងមានការភ័យណាស់ចំពោះសេចក្តីស្លាប់នេះ ការដែលនាងបានឃើញ ខ្មោចកណ្តាលផ្លូវ និងឃើញសាលីណាស្លាប់មួយអាទិត្យមុននេះ បានមក បន្លាចនាងឲ្យរន្ធត់មែនទែន ។ នាងបានត្រដររដកដង្ហើមចង់រស់ខ្លាំង ណាស់ តែនាងធ្វើមិនបាន ។ ពេលព្រឹកឡើង រូបរាងដ៏តូចរបស់នាងត្រូវ បានគេសែងទៅកប់ក្នុងព្រៃ ។

ឥឡូវនេះខ្ញុំបាននៅតែម្នាក់ឯងពិតប្រាកដណាស់ ។ ប៉ុន្តែមិនដឹង យ៉ាងម៉េចបានជាខ្ញុំដឹងដោយវិញ្ញាណថា មានព្រះគង់ជាមួយខ្ញុំដែរ គ្រាន់ តែខ្ញុំបានមានការខកចិត្តជាខ្លាំង ហើយខឹងព្រះអង្គ ។ ជារឿយៗ ខ្ញុំតែង តែស្រែកយ៉ាងខ្លាំងៗទៅរកព្រះអង្គទាំងទឹកភ្នែកថា "តើទេវតាខ្វាក់ភ្នែក ទេឬ? តើទេវតាទៅឯណាអស់ហើយ ទុកមនុស្សអាក្រក់ឲ្យរស់នៅដូច្នេះ"

ភាពតែលតោលម្នាក់ឯង និងទុក្ខសោកក្នុងចិត្តបានបន្ថែមមកលើរូបសាច់ដែលស្គាំងស្គមស្រាប់នោះ វាធ្ងន់ហួសប្រមាណស្ទើរតែទ្រាំលែងរួច ។

ក្នុងរយៈពេលបីខែក្រោយមក ខ្ញុំធ្លាក់ខ្លួនឈឺក្បែរៗតែនឹងស្លាប់ជាច្រើនដង ។ ជាច្រើនសាណាស់ដែលខ្ញុំមានជំងឺគ្រុនចាញ់ គ្រុនក្តៅផង រងារផងលាយឡំគ្នារណ្តំធ្មេញឥតឈប់ឈរ ។ ប៉ុន្តែកាលណាខ្ញុំមានកម្លាំងបន្តិចបន្តួចនោះ មេខ្មែរក្រហមបញ្ជាឲ្យខ្ញុំទៅធ្វើស្មៅពោតនៅចំការ ។ នៅពេលនោះ ខ្ញុំបានឃើញសេចក្តីមេត្តាករុណារបស់ព្រះ ជាពិសេសគឺនៅក្នុងចំការ ខ្ញុំបានធ្វើស្មៅជើងពោតម្នាក់ឯង ពេលខ្ញុំរងារខ្លាំង ព្រះជាម្ចាស់ទ្រង់បានបើកថ្ងៃក្តៅចំពីលើខ្លួនខ្ញុំ ពេលខ្ញុំបាត់រងារហើយប្រែទៅជាគ្រុនក្តៅវិញនោះ ព្រះជាម្ចាស់បានបញ្ជូនពពកបាំងថ្ងៃមិនឲ្យក្តៅមកលើខ្ញុំទៀត ។ រឿងនេះកើតឡើងជារៀងរាល់ថ្ងៃប្រហែលជាប្រាំមួយខែពេលដែលខ្ញុំឈឺជាទម្ងន់នោះ ។ ពេលដែលខ្ញុំគិតពិចារណាពីរឿងហ្នឹងឡើង ខ្ញុំក៏ឆ្ងល់ថា តើអ្នកណាបានថែរក្សាខ្ញុំយ៉ាងដូច្នេះ ប្រហែលជាទេវតារបស់ព្រះអង្គហើយ ដែលតាមថែរក្សាខ្ញុំ ។

បន្ទាប់មកទៀត ពួកមេខ្មែរក្រហមបានប្រើឲ្យខ្ញុំរែករបស់ធ្ងន់ៗពេក ភ្នែកខ្ញុំក៏ងងឹត ប៉ុន្តែខ្ញុំបានយកសាជូរដែលប្តីខ្ញុំឲ្យ យកទៅបុកឲ្យម៉ត់ ហើយបុកសំបកដើមកន្ទួតស្រុកឲ្យម៉ត់ រួចចាក់ចូលគ្នាបុកម្តងទៀតឲ្យម៉ត់ ហើយលាយទឹក រួចច្រោះយកទឹកថ្លាទុកក្នុងដបតូចមួយសំរាប់បន្តក់ចូលភ្នែក អស់រយៈកាលបីថ្ងៃភ្នែកខ្ញុំបានជាឡើងវិញ ។ ពិតមែន គឺព្រះជាម្ចាស់បានប្រទានអ្វីដែលខ្ញុំត្រូវការ ។

ពួកមេខ្មែរក្រហមមិនមែនអាក្រក់ទាំងអស់ទេ ។ មានម្នាក់ជាអ្នកដឹកនាំនៅចំការបានសំគាល់ថា ខ្ញុំជាអ្នកធ្វើការស្វិតស្វាញទទួលខុសត្រូវក្នុងការងារ ក្នុងកងកាប់ព្រៃ (ដើមណាដែលមានអង្រ្កងមានតែមេកងកាត់តែម្នាក់ឯង ខ្ញុំចូលទៅជួយកាប់រាល់ពេល) សូម្បីតែខ្ញុំមានជម្ងឺក៏ដោយ ក៏

ខ្ញុំនៅតែទៅធ្វើការ ដូច្នេះហើយបានជាអ្នកដឹកនាំនៅចំការបានចូលមកសុំយកខ្ញុំទៅធ្វើចំការជាមួយគាត់ ហើយមានសិទ្ធិចូលក្នុងឃ្លាំងល្ពៅតាមគាត់ប្រើនៅក្នុងមុខងារនេះ ខ្ញុំបានទទួលចំណីអាហារគ្រប់គ្រាន់ ហើយរូបសាច់ខ្ញុំក៏រីកចំរើន មានកម្លាំងឡើងវិញ ។

ប្រហែលមួយឆ្នាំកន្លះក្រោយមក បន្ទាប់ពីបានមកលេងជាមួយខ្ញុំនិងកូនលើកទីមួយ ប្ដីខ្ញុំបានត្រឡប់មកលេងជាលើកទីពីរ ពេលនោះគឺមានតែខ្ញុំម្នាក់ដែលសល់ពីស្លាប់ ។ ប្ដីខ្ញុំបានអង្វរខ្ញុំទាំងទឹកភ្នែកឲ្យខ្ញុំបង្ហាញផ្នូរដែលកប់ខ្មោចកូនៗ ប៉ុន្តែខ្ញុំបាននិយាយថា "បងអើយ ជីវិតកូនយើងផុតទៅហើយ សូមកុំរស់នៅក្នុងអតីតកាលអី សូមបងគិតពីជីវិតខ្លួន ហើយគិតពីអនាគតវិញ" ។

បន្ទាប់មកយើងបានឱបគ្នាយំ ហើយនិយាយគ្នានៅក្រោមដើមឈើកណ្ដាលចំការឪឡឹក នៅពេលយប់នោះព្រះច័ន្ទបានរះពេញវង់ ។ យប់នោះ ជាយប់ដែលខ្ញុំមានភាពស្និទ្ធស្នាលជិតដិតជាមួយប្ដីខ្ញុំជាងពេលមុនៗ ។ រួចគាត់បានអង្វរខ្ញុំថា ឲ្យរត់ទៅជាមួយនឹងគាត់ចេញទៅប្រទេសសៀម ។ ប៉ុន្តែខ្ញុំបានប្រាប់គាត់ថា ទោះបីកូនស្លាប់អស់ក៏ដោយខ្លួនខ្ញុំមួយក៏អាចធ្វើឲ្យដំណើរគាត់យឺតបានដែរ ហើយអាចបណ្ដាលឲ្យគេចាប់បានទាំងពីរនាក់ទៀតផង ។ ខ្ញុំបានកំឡាទឹកចិត្តគាត់ឲ្យរត់ទៅប្រទេសសៀមតែម្នាក់ឯង រួចគាត់នឹងអាចរកផ្លូវជួយសង្គ្រោះខ្ញុំជាក្រោយទៀត ។ ហើយពេលដែលយើងបានលាគ្នានោះ គឺជាពេលចុងក្រោយបំផុត ។ តាំងពីពេលនោះមក ខ្ញុំមិនដែលឃើញមុខប្ដីខ្ញុំទៀតទេ រហូតមកដល់ថ្ងៃនេះខ្ញុំក៏មិនដឹងថាគាត់ស្លាប់ ឬរស់ដែរ ។ បន្ទាប់ពីប្ដីខ្ញុំលាចេញពីខ្ញុំទៅ មេខ្មែរក្រហមក៏ចាប់បញ្ជូនខ្ញុំពីជុំរំមួយទៅជុំរំមួយ ពីស្រែមួយទៅស្រែមួយតាមរដូវកាល ។ ម្ដងនេះទៀតខ្ញុំបានធ្វើការងារធ្ងន់ៗ ហើយគេចែកអាហារមិនគ្រប់គ្រាន់ មានតែបាយលាយនឹងអំបិល ។ មានថ្ងៃមួយនោះ ខ្ញុំបាន

ដើរតាមភ្លឺស្រែក្រោមដំណក់ភ្លៀងយ៉ាងខ្លាំង ខ្ញុំបានស្រែកច្រៀងចំរៀងមួយដែលខ្ញុំចេះតាំងពីក្មេងមក ហើយបន្ថែមពាក្យខ្ញុំខ្លះ ដែលមានពាក្យថា "វាលវែងឆ្ងាយ មើលពីចម្ងាយស្ពាយស្រណោះ រកអនាគតពុំឃើញសោះ ឃើញតែសម្រស់វាលស្រែ" រួចខ្ញុំក៏និយាយទៅរកព្រះថា "ឱព្រះជាម្ចាស់អើយ...តើថ្ងៃណាទៅដែលជីវិតខ្លោចផ្សានេះត្រូវចប់?" ខ្ញុំបានឮសម្លេងដ៏ស្រទន់នៅក្នុងខ្ញុំ ប្រាប់ខ្ញុំថា *"ចូរអត់ធ្មត់ ហើយរង់ចាំចុះ អ្វីៗនឹងផ្លាស់ប្រែមិនខាន!"* ។

ខ្ញុំក៏បានពិចារណាខ្លួនឯងថា "ពិតប្រាកដជាត្រូវណាស់អ្វីៗក្នុងប្រវត្តិសាស្ត្រតែងតែផ្លាស់ប្តូរពីមួយជំនាន់ទៅមួយជំនាន់ ។ បន្ទាប់ពីភ្លៀងធ្លាក់ គឺមានថ្ងៃរះ ដូចជាលោកយាយខ្ញុំគាត់បានបង្រៀនខ្ញុំផងដែរ ។ តាំងពីថ្ងៃនោះមក ខ្ញុំបានកប់ទុកការល្វើងជូរចត់របស់ខ្ញុំជ្រៅទៅក្នុងបេះដូងខ្ញុំ ។ ទោះមានការអ្វីកើតឡើងក៏ដោយ ខ្ញុំតែងតែពាក់ទឹកមុខញញឹម ហើយរង់ចាំដោយសន្តិភាពនូវអនាគតល្អ ដែលនឹងមកដល់ដោយចិត្តសង្ឃឹម" ។

រដូវចម្រូតបានកន្លងផុតទៅ មេខ្មែរក្រហមបានបញ្ជូនខ្ញុំទៅជីកប្រឡាយទឹកយ៉ាងធំ នៅជុំវិញមុនៗដែលខ្ញុំធ្លាប់បាននៅពីមុន គឺខ្ញុំបានឃើញមនុស្សស្លាប់ដោយការអត់អាហារ ។ ប៉ុន្តែនៅទីនេះខ្ញុំបានឃើញមនុស្សស្លាប់ដោយគេសំលាប់ ការមួយទៀតដែលរំខានខ្ញុំយ៉ាងខ្លាំង គឺគេឲ្យក្មេងតូចៗធ្វើការហាលថ្ងៃក្តៅដូចជាទាសករ ។ ពេលណាដែលខ្ញុំបានឃើញទិដ្ឋភាពនោះ ខ្ញុំបែរទៅជាអរគុណព្រះជាម្ចាស់ដែលកូនខ្ញុំបានស្លាប់ផុតមិនបាននៅរងទុក្ខវេទនាដូចជាក្មេងទាំងនោះ ។

នៅខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយលុកប្រទេសកម្ពុជា ហើយបានដេញពួកខ្មែរក្រហមចេញពីទីក្រុងភ្នំពេញ ។ ពេលដែលខ្មែរក្រហមកំពុងតែរត់ចេញគេចពីខ្មាំងសត្រូវ មានមេដឹកនាំខ្មែរក្រហមជាច្រើនបានស្លាប់ ។

មេដឹកនាំខ្មែរក្រហមជាច្រើននាក់បានកាប់សម្លាប់អ្នកធ្វើការនៅក្នុងជុំរំ ដែលជាកន្លែងការដ្ឋានរបស់គេ ដោយព្រោះតែអំណាចចុងក្រោយរបស់គេត្រូវរលំរលាយ ។ មានកុមារជាច្រើននាក់ធ្វើការនៅក្នុងការដ្ឋានរបស់យើងត្រូវគេសម្លាប់ ដោយសារតែគេជាក្មេងកំព្រា ។ តែដោយសារព្រះគុណរបស់ព្រះជាម្ចាស់ ខ្ញុំបានរួចជីវិត ។ តែទោះជាយ៉ាងណាក៏ដោយទម្រាំតែទាហានវៀតណាមបានទៅរំដោះយើង ឲ្យរួចពីចំណាងរបស់ខ្មែរក្រហមដល់កន្លែងដែលយើងរស់នៅនោះ គឺរហូតដល់ខែមេសានៅក្នុងឆ្នាំនោះ ។ ការដ្ឋានភាគច្រើនចាប់ផ្ដើមឡើងមានមនុស្សរាប់រយនាក់ ហើយនៅពេលចុងបញ្ចប់ មានមនុស្សតិចតួចណាស់ដែលនៅរស់រានមានជីវិត ។

នៅពេលដែលពួកមេខ្មែរក្រហមបានរត់គេចចូលទៅក្នុងព្រៃជ្រៅ ដោយព្រោះតែទាហានវៀតណាមកាន់តែខិតចូលមកជិតដល់នោះ យើងនាំគ្នាប្រមូលឥវ៉ាន់បន្តិចបន្តួចរបស់យើង ដែលយើងបានទៅទម្លាយឃ្លាំងខ្មែរក្រហមនោះ ហើយក៏នាំគ្នារត់សំដៅទៅរកថ្នល់ធំ (ថ្នល់ជាតិ) ដើម្បីទៅជួបនឹងទាហានវៀតណាម ។ បន្ទាប់ពីយករបស់មានតម្លៃខ្លះៗពីយើងរួចមក ទាហានវៀតណាមបានដោះលែងឲ្យយើងទៅតាមដែលចិត្តយើងចង់ទៅ ។ ប៉ុន្តែ គេបានព្រមានយើងមិនឲ្យយើងទៅតាមផ្លូវទៅស្រុកថៃឡើយ ពីព្រោះមានមីនច្រើន ហើយនៅតែមានពួកខ្មែរក្រហមចាំវាយឆ្មក់នៅឡើយ ។

ក្រុមរបស់យើងនាំគ្នាដើរដោយជើងទទេ រយៈពេល២៨ថ្ងៃទើបបានមកដល់ភ្នំពេញ យើងរស់នៅដោយសារម្ហូបអាហារដែលយើងយកបានមកបន្តិចបន្តួចនោះ ។ ដំបូងខ្ញុំមានកម្លាំងចិត្តយ៉ាងខ្លាំងដោយមានសេចក្ដីសង្ឃឹមថា នៅពេលដែលខ្ញុំទៅដល់ផ្ទះ ខ្ញុំប្រហែលជាអាចជួបប្ដីនិងកូនស្រីពៅរបស់ខ្ញុំកំពុងរង់ចាំខ្ញុំនៅឯផ្ទះ ។ ប៉ុន្តែឆាកវិនាសកម្មរង

ចាំស្វាគមន៍គ្រប់ទិសទីកន្លែងទាំងអស់ និងមានគេប្រាប់ខ្ញុំនៅតាមផ្លូវពីរឿងរ៉ាវវេទនាជាច្រើន ពេលនោះក្តីសង្ឃឹមរបស់ខ្ញុំត្រូវរលាយ ។ ពេលនោះទៅជិតដល់ភ្នំពេញទៅហើយ នៅសល់តែប៉ុន្មានម៉ោងទៀត ប៉ុណ្ណោះ ខ្ញុំស្ទើរតែសម្រេចចិត្តឈប់នៅទីនោះ ហើយនិងធ្វើស្រែជាមួយអ្នកស្រុកគេនៅទីនោះ ។ ប៉ុន្តែពេលនោះ ខ្ញុំបានជួបក្មេងកំព្រាពីរបីនាក់ដែលមិនអាចចិញ្ចឹមខ្លួនឯងបាន ។ ដោយហេតុដូច្នេះ ខ្ញុំក៏ប្តូរគំនិតនិងបានសម្រេចចិត្តនាំពួកគេមកភ្នំពេញ និងជួយគេរកការងារធ្វើ ។

ខ្ញុំបានទុកក្មេងកំព្រាជាមួយមិត្តភក្តិ និងបានធ្វើដំណើរទៅភ្នំពេញដើម្បីស្វែងរកការងារ ។ ប៉ុន្តែកន្លែងដែលខ្ញុំចង់ទៅឃើញមុនគេនោះ គឺជាផ្ទះរបស់ខ្ញុំផ្ទាល់ ។ នៅតាមផ្លូវ ខ្ញុំបានឃើញសៀវភៅនៅរាយប៉ាយ ដោយសារតែមានមនុស្សរើបណ្ណាការយករបស់របរ ។ ខ្ញុំមិនបានអានសៀវភៅជាច្រើនឆ្នាំហើយ ដូច្នេះខ្ញុំក៏យកកញ្ជើមួយដែលនៅក្បែរផ្លូវនោះប្រមូលសៀវភៅដាក់ឲ្យពេញតាមដែលខ្ញុំអាចដាក់បាន ។ នៅពេលដែលខ្ញុំទូលកញ្ជើសៀវភៅដើរតាមផ្លូវនោះ ខ្ញុំបានឃើញពួកវៀតណាមឡើងនៅផ្ទះស្អាតៗ រួចអស់ទៅហើយ ។ ជនភៀសខ្លួនបានឡើងទៅនៅផ្ទះដែលមិនស្អាត ដែលមិនសូវមានគេចង់បាន ។ ប៉ុន្តែផ្ទះដែលបាក់បែកប្រើមិនកើតនោះគ្មានមនុស្សនៅទេ មានទ្វារនៅចំហច្លងទៅវិញ ។

ខ្ញុំបានលូកដៃក្នុងហោប៉ៅរបស់ខ្ញុំ ដើម្បីទាញយកកូនសោ ដែលខ្ញុំបានខំរក្សាទុកជាយូរមកហើយ ពេលដែលរស់នៅក្នុងព្រៃនោះ ។ បន្ទាប់មក ខ្ញុំបានឈរនៅពីមុខផ្ទះរបស់ខ្ញុំ ។ ខ្ញុំក៏បានឃើញទ្វារផ្ទះរបស់ខ្ញុំបើកចំហដែរ ។ ខ្ញុំបានដើរចូលទៅក្នុងផ្ទះដោយមានកាន់សោនៅនឹងដៃ ។ គ្មានសល់របស់របរអ្វីបន្តិចនៅក្នុងផ្ទះឡើយ ។ ភ្នែកខ្ញុំខំសម្លឹងមើលដោយអន្ទះសាទៅរកកន្លែងដែលខ្ញុំលាក់សៀវភៅដាក់រូបថតរបស់យើង ប៉ុន្តែកន្លែងនោះពិដានរបើកអស់រលីង ខ្ញុំគ្មានសល់អ្វីឡើយ ខ្ញុំគ្រាន់តែ

បានឃើញថ្ងៃចាំងចូលកន្លែងនោះតែប៉ុណ្ណោះ ។ គ្មាននរណាម្នាក់ដែលខ្ញុំស្គាល់នៅក្បែរកន្លែងខ្ញុំនៅនោះឡើយ ។ គ្មានឃើញសំបុត្រស្នាមអ្វីពីប្ដីរបស់ខ្ញុំដែលបានបិទទុកនៅទីនោះសោះដែរ ។ ក្ដីសង្ឃឹមរបស់ខ្ញុំក៏ចាប់ផ្ដើមរលាយទៅអស់នៅពេលនេះម្ដងទៀត ។

ខ្ញុំបានទៅខាងក្រៅផ្ទះ ហើយបានអង្គុយចុះសំរាកនៅក្បែរផ្លូវ ។ មានក្មេងប្រុសម្នាក់អាយុស្របាលនឹងកូនខ្ញុំដែលស្លាប់នៅទីនោះ បានរត់សំដៅមករកខ្ញុំ ហើយនិយាយថា "មីង! សៀវភៅនៅក្នុងកញ្ជើជារបស់មីងឬ?" "អើ មែនហើយ វាជារបស់មីង" "ឲ្យខ្ញុំសុំមួយក្បាលបានទេមីង?" ខ្ញុំបានឆ្លើយតបថា "អើ យកបី ឬបួនក្បាលទៅ" "មែន? បី ឬបួនក្បាលមែន?" គាត់បានសួរខ្ញុំបញ្ជាក់ ។ "អើ មែនហើយ យកទៅក្មួយ" ។ ក្មេងនោះបានជ្រើសរើសសៀវភៅយកបី ឬបួនក្បាល ហើយក៏រត់ចេញដោយទឹកមុខរីករាយ ។ មួយស្របក់ក្រោយមក ក្មេងប្រុសនោះក៏ត្រឡប់មកវិញ ។ "មីង យប់នេះមីងសំរាកនៅកន្លែងណា?" ខ្ញុំឆ្លើយថា "ប្រហែលជានៅចិញ្ចើមផ្លូវនេះឯង" ។ បន្ទាប់មកក្មេងនោះតបថា "ម៉ែខ្ញុំប្រាប់ខ្ញុំឲ្យមកអញ្ជើញមីងទៅសម្រាន្តនៅផ្ទះល្វែងរបស់យើង ។"

ដូច្នេះខ្ញុំបានទៅជាមួយក្មេងប្រុសនោះ ទៅដល់ផ្ទះរបស់គាត់ ។ ម្ដាយរបស់គាត់ចេញមកទទួលខ្ញុំដល់មាត់ទ្វារផ្ទះ ហើយទទួលរាក់ទាក់ខ្ញុំយ៉ាងកក់ក្ដៅបំផុត ។ ប៉ុន្ដែនៅពេលដែលខ្ញុំចូលទៅក្នុងផ្ទះ ខ្ញុំបានឃើញរបស់របរទាំងអស់ គឺគេបានយកចេញពីផ្ទះរបស់ខ្ញុំ តាំងពីតុបាយ កៅអីសាឡុង ម៉ាស៊ីនដេរ និងរបស់របរដទៃទៀត ។ នៅពេលដែលខ្ញុំបើកទ្វារបន្ទប់ដែលខ្ញុំត្រូវសម្រាកមួយយប់នៅទីនោះ គ្រាន់តែទ្វាររបើកឡើងភ្លាម ខ្ញុំបានឃើញសម្លៀកបំពាក់របស់ប្ដីខ្ញុំ និងកូនប្រុសខ្ញុំដែលគេបានព្យួរនៅទីនោះ ។ ខ្ញុំញញឹមដើម្បីបន្លប់នូវការឈឺចាប់ពើតផ្សានៅក្នុងចិត្តរបស់ខ្ញុំ

ហើយបាននិយាយសម្តែងនូវការអរគុណ ដែលគេបានអនុញ្ញាតឲ្យខ្ញុំស្នាក់នៅចំពោះទឹកចិត្តដ៏សប្បុរសរបស់គេ ។ ក្រោយពីអរគុណគេរួចហើយ ខ្ញុំដេកយំខ្សឹកខ្សួលតែឯងនៅក្នុងបន្ទប់នោះ ។

នៅពេលព្រឹកស្អែកឡើង ខ្ញុំរកបានការងារសំរាប់ខ្លួនខ្ញុំ និងសំរាប់ពួកក្មេងកំព្រានៅឯកំពង់ផែ ។ ក្រោយមក ខ្ញុំក៏វិលត្រឡប់ទៅស្រុកស្រែវិញដើម្បីទៅទទួលពួកក្មេងៗមកធ្វើការ ។ ក្មេងៗទាំងនោះគេមានកម្លាំងរឹងមាំគ្រប់គ្នា ដូច្នេះការងាររបស់គេនោះត្រូវលីបាវចុះទូក និងឡើងពីទូក ។ ការងាររបស់ខ្ញុំ គឺមើលថែសួនជីគ្រប់មុខ ។

ក្រោយមកមានស្ត្រីមេការម្នាក់ ដែលនៅឯកំពង់ផែបានសុំខ្ញុំឲ្យធ្វើជាអ្នកមើលការខុសត្រូវជាអ្នកចាត់ចែងការងារមេការលើស្ត្រី ។ គាត់បាននិយាយថា ខ្ញុំមិនមែនជាមនុស្សដែលបង្កបញ្ហាឡើយ ។ ខ្ញុំមិនចង់ធ្វើជាមេការសោះ ប៉ុន្តែនៅទីបំផុតគាត់បានអង្វរបបួលខ្ញុំរហូតដល់ខ្ញុំព្រមឈរឈ្មោះឲ្យគេបោះឆ្នោតរើស ។ គេបានជ្រើសរើសខ្ញុំឲ្យធ្វើជាមេការមើលការខុសត្រូវលើកម្មករស្ត្រីៗនៅកំពង់ផែ ។

ប៉ុន្តែមិនយូរប៉ុន្មាន មេការផ្នែកកម្មករបុរសមកពីប្រជុំបុគ្គលិកវិញ គាត់បាននាំយកនូវបទបញ្ជាមួយមកឲ្យខ្ញុំ គាត់បាននិយាយជាមួយខ្ញុំថា ខ្ញុំត្រូវធ្វើបញ្ជីឈ្មោះកម្មការិនី ដែលធ្វើការនៅកំពង់ផែទាំងអស់ដែលមានជាប់សែស្រឡាយជាជនជាតិចិន ។ មុនដំបូងខ្ញុំបានសុំឲ្យគាត់ធ្វើបញ្ជីនោះដោយខ្លួនឯង ព្រោះថាគាត់បានទៅប្រជុំ ហើយបានទទួលបទបញ្ជានោះផ្ទាល់ ។ តែគាត់មិនបានយល់ព្រមឡើយ ។

បន្ទាប់ពីគាត់បានចេញទៅបាត់ ខ្ញុំគិតដោយខ្លួនឯងថា "ឥឡូវនេះការកាប់សម្លាប់ នឹងចាប់ផ្តើមម្តងទៀតហើយ ។ បើខ្ញុំព្រមធ្វើបញ្ជីនេះខ្ញុំត្រូវតែដាក់ឈ្មោះរបស់ខ្ញុំនៅលើគេបង្អស់ ដោយព្រោះថា ជីតារបស់ខ្ញុំជាជនជាតិចិន ។ ពេលនោះខ្ញុំក៏ត្រូវស្លាប់ជាមួយគេដែរ ។ ប៉ុន្តែបើខ្ញុំ

បដិសេធន៍មិនធ្វើតាមបទបញ្ជានោះ ពេលនោះក៏ត្រូវស្លាប់ដែរ ។" ពេលនោះឯង ជាពេលដែលខ្ញុំសម្រេចចិត្តរត់គេចខ្លួនទៅប្រទេសថៃ ។ មធ្យោបាយនោះ យ៉ាងហោចណាស់ខ្ញុំអាចមានឱកាសរស់តិចតួចណាស់ដែរ ។

ប៉ុន្តែឥឡូវនេះ តើអាចឲ្យខ្ញុំធ្វើយ៉ាងណា? បើខ្ញុំមិនស្គាល់ផ្លូវទាល់តែសោះនោះ ។ ខ្ញុំគ្មានលុយសោះ ដោយព្រោះថា តម្លៃឈ្នួលធ្វើការនៅកំពង់ផែ គេបានចេញថ្លៃឈ្នួលឲ្យខ្ញុំគិតជាអង្ករ ។ ពេលនោះហើយដែលខ្ញុំសម្រេចចិត្តទូលថ្វាយព្រះជាម្ចាស់ចំពោះកិច្ចការនោះ ។ ខ្ញុំងើយមើលទៅលើ ហើយខ្ញុំនិយាយថា "ព្រះអម្ចាស់យេស៊ូអើយ បើព្រះអង្គពិតជានៅទីនោះមែន សូមព្រះអង្គជួយដល់ខ្ញុំម្ចាស់ផង ។"

មិនយូរប៉ុន្មាន មានបុរសម្នាក់បានមកសុំឲ្យខ្ញុំជួយទៅរកប្រពន្ធរបស់គាត់នៅក្នុងជុំរុំជនភៀសខ្លួន នៅឯស្រុកថៃ ។ គាត់បាននិយាយថា គាត់ស្គាល់ផ្លូវឆ្លងកាត់ព្រំដែន ។ តើខ្ញុំត្រូវទៅជាមួយគាត់ឬ? ព្រះជាម្ចាស់ចាត់អ្នកនាំផ្លូវដល់ខ្ញុំរបៀបនោះឯង ។ ខ្ញុំបានសុំគាត់រយៈពេល៥ថ្ងៃដើម្បីរៀបចំខ្លួន តែគាត់និយាយថា គាត់អាចចាំបានត្រឹមតែបីថ្ងៃប៉ុណ្ណោះ ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំនឹងព្យាយាមដើម្បីរៀបចំខ្លួនឲ្យរួច ។

ខ្ញុំបានសម្រេចចិត្តទូលថ្វាយទៅព្រះជាម្ចាស់ម្ដងទៀត ។ "ព្រះអម្ចាស់យេស៊ូអើយ បើព្រះអង្គពិតជានៅទីនោះមែន សូមព្រះអង្គប្រទានលុយកាក់ដល់ខ្ញុំម្ចាស់ក្នុងរយៈពេលបីថ្ងៃក្រោយទៀត ។ ខ្ញុំម្ចាស់មិនមែនលោភទេ សូមប្រទានឲ្យខ្ញុំម្ចាស់គ្រប់គ្រាន់ក្នុងការធ្វើដំណើរទៅនោះបានហើយ" ។

ថ្ងៃក្រោយពីនោះមក មានបុរសម្នាក់មកសុំទិញរបស់របរខ្លះៗដែលខ្ញុំមាន ។ ខ្ញុំបានគិតនៅក្នុងចិត្តរួចទៅហើយពីតម្លៃដែលសមរម្យដែលខ្ញុំត្រូវលក់ តែគាត់បែរជាឲ្យថ្លៃជាមាសចំនួនពីរដងនៃការដែលខ្ញុំគិតទុកទៅទៀត ខ្ញុំរំភើបចិត្តយ៉ាងខ្លាំង ។ មិនគ្រាន់តែប៉ុណ្ណោះទេ ប្រាក់ខែ

នៅឯកំពង់ផែ គេចាប់ផ្តើមចេញថ្លៃជាប្រាក់ លែងឲ្យជាអង្ករទៀតហើយ! របៀបនោះឯង ដែលព្រះជាម្ចាស់ប្រទានពរជាប្រាក់កាសដល់ខ្ញុំ ។

ដូច្នេះនៅពេលដល់ថ្ងៃកំណត់របស់មេខ្យល់ ដែលថានឹងមកយកខ្ញុំនៅថ្ងៃទីបី ខ្ញុំត្រូវត្រៀមលុយជាស្រេច ។ យើងដឹងនៅតាមជនបទ មានទាហានបីភាគីដែលកំពុងចង់កាន់កាប់អំណាចគ្រប់គ្រង ភាគីទាំងនោះ គឺទាហានវៀតណាម កងទ័ពសេរីការ និងកងទ័ពខ្មែរក្រហម ។ ប៉ុន្តែនៅពេលដែលយើងធ្វើដំណើរដោយថ្មើរជើងកាត់តំបន់ជាយដែននោះ គួរឲ្យអស្ចារ្យណាស់ គ្រប់កន្លែងទាំងអស់គ្មានការបាញ់ប្រហារគ្នារវាងភាគីទាំងនោះឡើយ ។ កន្លែងដែលយើងទៅដល់ គ្រាន់តែយើងចេញផុតភ្លាមស្រាប់តែមានការបាញ់ប្រហារគ្នាភ្លាម ។

ទីបំផុត យើងក៏បានទៅដល់ព្រំប្រទល់ តែចំណែកផ្លូវចុងក្រោយដែលយើងត្រូវធ្វើដំណើរនោះ មានគ្រោះថ្នាក់ជាទីបំផុត ។ នៅពេលយប់ងងឹតសូន្យឈឹង យើងដើរកាត់ព្រៃយ៉ាងក្រាស់ដែលពោរពេញទៅដោយគ្រាប់មីន ឬជាកន្លែងដែលមានពួកខ្មែរក្រហមពួនសម្ងំលាក់ខ្លួន ។ មេខ្យល់របស់ខ្ញុំបាននាំមនុស្សដទៃទៀតទៅជាមួយខ្ញុំដែរ ។ នៅពេលដែលគាត់បាននាំក្រុមរបស់យើងចូលទៅក្នុងព្រៃ មានអ្នកស្រុកដែលរស់នៅក្បែរទីនោះបានមកពីក្រោយខ្នងយើង ហើយនិយាយថា "ឈប់ សិន! សូមទៅផ្លូវនោះ បើពុំនោះទេអ្នកទាំងអស់គ្នានឹងដើរចូលទីបញ្ជាការរបស់ខ្មែរក្រហមហើយ!" ព្រះជាម្ចាស់បានសង្គ្រោះម្តងទៀតឲ្យរួចពីគ្រោះថ្នាក់ដ៏សាហាវនោះ ។

ក្រុមរបស់យើងនាំគ្នាប្តូរទិសដៅនៃការធ្វើដំណើរ ដោយដើរកាត់ព្រៃដែលមានវល្លិចាក់ស្រេះលើគ្នា ។ មុនដំបូង មេខ្យល់របស់ខ្ញុំគាត់ជួយវែកផ្លូវឲ្យខ្ញុំដើរ តែបន្ទាប់មកគាត់ទៅជួយដល់យាយចាស់ម្នាក់ដែលមានចៅតូចមួយនៅពនឹងដៃ ។ ពេលនោះ ខ្ញុំមានជំងឺខ្វាក់មាន់ មិនប៉ុន្មាននាទី

ផងខ្ញុំដឹងថា ខ្ញុំវង្វេងពីក្រុមនៅកណ្ដាលព្រៃតែម្នាក់ឯង ។ ដើរបុកគល់ ឈើព្រោះខំព្យាយាមដើររកពួកគេ ហើយក៏ដើរធ្លាក់ក្នុងរណ្ដៅ ព្រោះមើលមិនឃើញ ។ តែខ្ញុំខ្លាចមិនហ៊ានស្រែកហៅឲ្យគេជួយ ក្រែងលោខ្មែរក្រហមនៅជិតនោះៗ ។

បន្ទាប់មក ខ្ញុំឈប់ដើម្បីដកដង្ហើមឲ្យវែងៗនឹងបានបាត់ហត់ ដើម្បីពិចារណារកមធ្យោបាយដោះស្រាយ ។ "ព្រះអម្ចាស់យេស៊ូ" ខ្ញុំអធិស្ឋានខ្សឹបៗនៅក្នុងចិត្ត "បើព្រះអង្គពិតជាព្រះជាម្ចាស់ពិតតែមួយមែន សូមព្រះអង្គជួយសង្គ្រោះខ្ញុំម្ចាស់ផង" ភ្លាមនោះ ខ្ញុំបានឃើញពន្លឺមួយតូចប៉ុនមេដៃនៅចំពោះមុខរបស់ខ្ញុំ ។ ខ្ញុំក្រោកឡើង ហើយដើរតាមពន្លឺនោះ ដែលនាំខ្ញុំឲ្យដើរកាត់ព្រំដែនទៅក្នុងជំរំជនភៀសខ្លួនដោយសុវត្ថិភាព ។

បន្ទាប់ពីស្នាក់នៅមួយរយៈពេលខ្លី ពីជំរុំមួយទៅជំរុំមួយជាច្រើនមក ខ្ញុំក៏មានឱកាសចេញទៅរស់នៅក្នុងសហរដ្ឋអាមេរិក ។ ពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានទទួលនូវព្រះគម្ពីរមួយក្បាល និងបានទទួលនូវការហ្វឹកហ្វឺននៅក្នុងព្រះវិហារជាលើកដំបូងបំផុត ។ ដោយសារតែការងាររបស់ព្រះវិញ្ញាណបរិសុទ្ធ ខ្ញុំត្រូវបានដោះឲ្យរួចពីឫសគល់នៃភាពជូរចត់ និងភាពចងគំនុំមិនចេះអត់ទោសឲ្យគេ ដែលដក់ជាប់នៅក្នុងចិត្តរបស់ខ្ញុំនោះ ខ្ញុំក៏បានរសាយបន្តិចម្ដងៗ ។ ឥឡូវនេះខ្ញុំក្រឡេកមើលក្រោយពីឆាកជីវិតរបស់ខ្ញុំ និងខ្ញុំឃើញព្រះហឫទ័យដ៏ស្មោះស្ម័គ្រ អំណាចចេស្ដា និងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលព្រះអង្គបានការពារ និងដោះខ្ញុំឲ្យរួចគ្រប់យ៉ាងទាំងអស់ ដែលពេលនោះខ្ញុំមិនអាចអរគុណដល់ព្រះអង្គបានឡើយ ។

ឥឡូវនេះ ខ្ញុំអាចមើលឃើញដែរថា ហេតុអ្វីបានជាព្រះជាម្ចាស់អនុញ្ញាតឲ្យខ្ញុំក្លាយជាកូនកំព្រា និងក្លាយជាមនុស្សដែលគ្មានអត្ថប្រយោជន៍អ្វីសោះនៅពេលដែលខ្ញុំស្ថិតនៅក្នុងបឋមវ័យនោះ ។ បទ

ពិសោធន៍នៃជីវិតក្នុងបឋមវ័យរបស់ខ្ញុំ បានជំរុញឲ្យខ្ញុំមានចំណុចរឹងប៉ឹង នៅក្នុងពេលក្រោយនៃការដែលព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំ ឲ្យរួមដៃជាមួយបងប្អូនអាមេរិកកាំងឈ្មោះ Gioia Micheloti ដើម្បីវិលនិវត្តន៍ចូលមកប្រទេសខ្មែរនៅឆ្នាំ ១៩៩៥ ដើម្បីបើកសាលាសំរាប់កុមារកំព្រា និងក្មេងអនាថា ដែលសាលានោះឈ្មោះថា "សាលាកិច្ចការសិល្បៈគ្រីស្ទានខ្មែរ"។

ដោយសារតែខ្ញុំពីក្មេងស្រឡាញ់សិល្បៈរបស់ខ្មែរ ទើបទីបំផុតធ្វើឲ្យខ្ញុំអាចច្នៃប្រឌិតចេញជាព័ន្ធកិច្ចនេះឡើង ។ ខ្ញុំក៏ដូចជាមិត្តភក្តិរបស់ខ្ញុំ Gioia អាចជួយឲ្យកុមារ និងយុវជនដែលគេបោះបង់ និងមានភាពខ្វះខាតខ្លាំងនៅក្នុងចិត្ត ឲ្យគេបានឃើញពីភាពពេញលេញ និងភាពដែលមានសារសំខាន់របស់គេ ដោយសារតែគេអាចសម្តែងចេញនូវអំណោយទានដែលប្រកបទៅដោយប្រឌិតញ្ញាណរបស់គេ ដូចជា (តន្ត្រី របាំ ល្ខោន គំនូរសិល្បៈ និងអក្សរសិល្ប៍) ដើម្បីបំរើដល់ព្រះអាទិកររបស់ខ្លួននោះ យើងបានស្វែងយល់ឃើញថា យើងផ្ទាល់បានទទួលនូវការប្រោសឲ្យជា និងបានសម្រេចកិច្ចការបាន ដោយសារតែយើងធ្វើរួមជាមួយនឹងពួកគេដែរ ។



សាលាកិច្ចការសិល្បៈគ្រីស្ថានខ្មែរ

HONEYCOMB 4/1 (January 2003): 158–170



# How God Turned my Mourning into Dancing

*Noren Vann Kim*
(Known as Tay Khonnang)

As I look back on my life, I can see God's divine intervention rescuing me from despair and disaster again and again. Reflecting on David's words in Psalm 30:11, I have come to view my life thus far exactly as he described—surely God has turned my mourning into dancing!

When I was very small, I once fell into a river and almost drowned, but God gave me wisdom to keep pushing with my feet against the bottom, propelling myself to the surface for periodic breaths. Then God sent some ducks to paddle near me and attract the attention of people on the bridge. By the grace of God, one of my relatives saw me bobbing up and down, and rushed to rescue me.

